ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សមិទ្ធផល

# វិស័យអប់រំ យុវជន និងកីឡា

## ពិព័រណ៍អាស៊ាន កូរ៉េ

ទីក្រុង ប៊ូសាន ថ្ងៃទី១១-១២ ខែធ្នូ ឆ្នាំ២០១៤

# មាតិកា


| | ទំព័រ |
|---|---|
| **១. ទស្សនវិស័យនៃការអភិវឌ្ឍជាតិ** | ១ |
| **២. ទស្សនវិស័យនៃការអភិវឌ្ឍធនធានមនុស្ស និងគោលនយោបាយអប់រំ** | ១ |
| **៣. សមិទ្ធផលវិស័យអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៣-២០១៤** | ៤ |
| ៣.១. ការអប់រំកុមារតូច | ៤ |
| ៣.២. ការអប់រំបឋមសិក្សា | ៥ |
| ៣.៣. ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ៦ |
| ៣.៤. ការអប់រំឧត្តមសិក្សា | ១០ |
| ៣.៥. ការអប់រំក្រៅប្រព័ន្ធ | ១១ |
| ៣.៦. ការអភិវឌ្ឍយុវជន | ១៣ |
| ៣.៧. ការអប់រំកាយ និងកីឡា | ១៤ |
| **៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ** | ១៥ |
| **៥. វិធានការកំណែទម្រង់** | ១៦ |

## ១. ទស្សនវិស័យនៃការអភិវឌ្ឍជាតិ ៖ ការអភិវឌ្ឍសេដ្ឋកិច្ចឱ្យមានការប្រកួតប្រជែង សុខដុមនីយកម្ម និងនិរន្តរភាព

ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជាគឺ កសាងសង្គមកម្ពុជាមួយដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម កំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍប្រកប ដោយចីរភាព និងសមធម៌ ការកែលម្អជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការការពារ បរិស្ថាន ការលើកស្ទួយវប្បធម៌ និងអត្តសញ្ញាណជាតិ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ ប្រជាធិបតេយ្យសេរីពហុបក្ស ព្រមទាំងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងមានកោសិការ ផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និងមាន ការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ ព្រមទាំងមានកិត្យានុភាព ខ្ពស់លើឆាកអន្តរជាតិ។

កម្ពុជាសង្ឃឹមថានឹងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ឈានទៅជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ ២០៥០។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅ យុទ្ធសាស្ត្រ ៤ រួមមាន **១)**ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំ ប្រមាណ ៧ ភាគរយ ប្រកបដោយចីរភាព **២)**បង្កើតការងារឱ្យបានកាន់តែច្រើនជូនដល់ប្រជាជន ពិសេសសម្រាប់ ស្រទាប់ យុវជន **៣)**សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង ១ភាគរយក្នុង មួយឆ្នាំ និង **៤)**បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ។

រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើវិស័យអភិវឌ្ឍធនធានមនុស្ស ដែលនឹងធានាបាន នូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ដែលកាន់តែបើកចំហរតាមរយៈ **១)**ការបណ្តុះបណ្តាល ពលករឱ្យមានជំនាញ និងផលិតភាពខ្ពស់តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើតតម្លៃបន្ថែមខ្ពស់ **២)**ការរៀបចំក្របខណ្ឌគតិយុត្ត និងកសាងស្ថាប័នអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **៣)**លើកទឹកចិត្ត វិស័យឯកជនឱ្យចូលរួមក្នុងកិច្ចការនេះ និង៤)ការពង្រឹងគុណភាពនៃការអប់រំ និងការលើកកម្ពស់ ការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍។

## ២. ទស្សនវិស័យនៃការអភិវឌ្ឍធនធានមនុស្ស និងគោលនយោបាយអប់រំ

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពសមត្ថភាព និងគុណធម៌គឺជាកត្តាគន្លឹះ សម្រាប់ ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងពេលចំពោះមុខ និងសម្រាប់អនាគត។

ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្សគឺសំដៅទៅលើការកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញការច្នៃប្រឌិត និងនវានុវត្តន៍លើគ្រប់ផ្នែកគ្រប់វិស័យពិសេសផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព្រមទាំងសមត្ថភាពក្នុងការស្រាវជ្រាវនិងការអភិវឌ្ឍ។ ទន្ទឹមនឹងនេះការលើកស្ទួយគុណភាពផ្នែកសុខភាព កាយសម្បទា សីលធម៌ ស្មារតីទទួលខុសត្រូវ និងមនសិការស្នេហាជាតិ និងវិជ្ជាជីវៈ ដោយគ្មានការរើសអើងខាងយេនឌ័ររួមជាមួយនឹងប្រព័ន្ធសុវត្ថិភាពសង្គមគត់មត់។

ប្រទេសកម្ពុជាបានឈានចូលក្នុងដំណាក់កាលមួយថ្មីទៀតនៃការអភិវឌ្ឍវិស័យអប់រំ ដែលចាំបាច់ត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើការពង្រឹងការអប់រំមូលដ្ឋាន និងគុណភាពសិក្សានៅក្នុង ក្របខ័ណ្ឌសេដ្ឋកិច្ចជាតិ ដែលមានលក្ខណៈជាប្រព័ន្ធដ៏ទូលំទូលាយ។ ចក្ខុវិស័យអប់រំសម្រាប់រយៈពេលវែង របស់កម្ពុជា គឺយកចិត្តទុកដាក់ផ្ដល់សេវាអប់រំចាប់ពីកុមារតូចតាមគ្រប់រូបភាព ដែលជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការអប់រំនៅកម្រិតបន្តបន្ទាប់ទៀត និងយកចិត្តទុកដាក់ដល់សិស្សានុសិស្សនៅកម្រិតដំបូងនៃបឋមសិក្សាលើបំណិនអំណាន និងលេខនព្វន្ត។ វិស័យអប់រំនឹងពង្រីកវិសាលភាពនៃការអប់រំសម្រាប់ទាំងអស់គ្នាពីបឋមសិក្សា ៦ ឆ្នាំ ទៅដល់អប់រំមូលដ្ឋាន ៩ ឆ្នាំ។ សិស្សានុសិស្សដែលបញ្ចប់ការសិក្សាអប់រំមូលដ្ឋាននឹងត្រូវពិនិត្យមើលឧបនិស្ស័យ ក្នុងការជ្រើសរើសបន្តការសិក្សានៅអប់រំមធ្យមសិក្សាចំណេះទូទៅ ឬក៏ជ្រើសរើសផ្នែកអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ។ ការលើកកម្ពស់គុណភាពនៃការអប់រំ ក៏ត្រូវផ្ដោតលើការលើកកម្ពស់គុណភាពរបស់ធាតុចូល ដំណើរការរៀន និងបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។ គុណភាពរបស់ធាតុចូលនឹងផ្ដោតសំខាន់លើគុណវុឌ្ឍិគ្រូបង្រៀន ដែលនឹងត្រូវបង្កើន រូបមន្តពី ១២ បូក ២ ទៅដល់ ១២ បូក ៤ នៅឆ្នាំ ២០២០ សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន និងមធ្យមសិក្សាបឋមភូមិ។ គុណភាពរបស់កម្មវិធីសិក្សានៅអប់រំចំណេះទូទៅ និងឧត្តមសិក្សាឱ្យស្របនឹងស្តង់ដារគុណភាពអាស៊ាន។

ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំជំរុញឱ្យវិស័យអប់រំ យុវជន និងកីឡាទាំងមូលអាចធ្វើការជាមួយគ្នា ដើម្បីឆ្លើយតបនឹងតម្រូវការសង្គម និងសេដ្ឋកិច្ច។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ជាឯកសារមគ្គុទេសក៍មួយដែលបានផ្ដោតលើអន្តរាគមន៍អប់រំតម្រង់ទៅដល់ក្រុមជួបការលំបាក ការផ្ដល់ការអប់រំប្រកបដោយគុណភាព និងភាពឆ្លើយតបសម្រាប់ការអភិវឌ្ឍប្រទេស។ ការផ្ដល់សេវាអប់រំប្រកបដោយវិជ្ជាជីវៈ និងគណនេយ្យភាព ជាមូលដ្ឋានសម្រាប់កសាងសង្គមមួយប្រកបដោយចំណេះដឹង និងជំនាញ។ វិស័យអប់រំនៅកម្ពុជានឹងរៀបចំនូវក្របខ័ណ្ឌធានាគុណភាពទូទាំងវិស័យ ដោយផ្អែកលើស្តង់ដារនៃការសិក្សារៀនសូត្រ និងការផ្ដល់សេវាដែលឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ សហគមន៍ និងទីផ្សារការងារ។

គោលនយោបាយអប់រំរយៈពេលមធ្យមចំនួន ៣ កំពុងត្រូវបានអនុវត្តមានដូចជា ៖

## *គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

កុមារកម្ពុជាគ្រប់រូបបានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងមានឱកាសបន្តការសិក្សាទៅមុខទៀត។ សម្រាប់កុមារដែលពុំមានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធជម្រើសផ្សេងទៀតនឹងត្រូវផ្តល់លទ្ធភាពឱ្យអ្នកទាំងនោះទទួលបានការអប់រំ។

ការបង្កើនចំនួនកុមារ និងយុវជន ឱ្យទទួលបានការអប់រំនៅគ្រប់កម្រិត ដោយផ្តោតលើសមធម៌ និងតំបន់ និងក្រុមកុមារជួបការលំបាក។ ការបង្កើនឱកាសដល់សិស្សដែលបញ្ចប់ការសិក្សា នៅថ្នាក់ទី១២ ឱ្យទទួលបាននូវចំណេះដឹង និងជំនាញក្នុងការគិតនិងវិភាគហេតុផល និងអាចជាមូលដ្ឋានសម្រាប់បន្តការសិក្សានៅក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងឧត្តមសិក្សាតទៅទៀត។

## *គោលនយោបាយទី ២ ៖លើកកម្ពស់គុណភាព និងភាពឆ្លើយតប*

កុមារ និងយុវជនគ្រប់រូបមានបទពិសោធក្នុងការសិក្សាប្រកបដោយគុណភាព និងភាពឆ្លើយតបដែលអាចឱ្យពួកគេចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។ ការធានាថា ការអប់រំប្រកបដោយគុណភាព និងមានទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេស។ ក្របខ័ណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សា មាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រង ជាមួយនឹងស្តង់ដារនៃផលសម្រេច ការពិនិត្យតាមដាននិងរបាយការណ៍។

## *គោលនយោបាយទី ៣ ៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*

ការផ្តល់សេវាអប់រំនឹងត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងវិជ្ជាជីវៈនឹងផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធផល) ទាន់ពេលវេលា ការពិនិត្យតាមដាន របាយការណ៍លទ្ធផល និងយោបល់ត្រឡប់ វិធានការប្រកបដោយគណនេយ្យភាព និងយន្តការសម្រាប់កែលម្អគោលនយោបាយ យុទ្ធសាស្រ្ត និងកម្មវិធីទាំងនៅថ្នាក់ជាតិទាំងនៅថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនឹងអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាព ទៅនឹងតម្រូវការជាក់ស្តែងនៅកម្រិតសាលារៀន។

## ៣. សមិទ្ធផលវិស័យអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០១៣-២០១៤

### ៣.១ ការអប់រំកុមារតូច

ក្រសួងបានរៀបចំគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលមានចក្ខុវិស័យ កុមារតូចទាំងអស់ចាប់ពីកកំណើតរហូតដល់អាយុក្រោម ៦ ឆ្នាំត្រូវទទួលបានសេវាគាំពារ និងអភិវឌ្ឍ ជាពិសេសកុមារតូចរងគ្រោះ កុមារតូចងាយរងគ្រោះ និងក្រខ្សត់ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។





ក្រសួងបានកែលម្អបរិស្ថានសាលារៀន ថ្នាក់រៀន និងការផ្តល់អាហារពេលព្រឹកអាចរក្សានិរន្តរភាពនៃការសិក្សារបស់កុមារ។ ការពង្រីកថ្នាក់មត្តេយ្យក្នុងសាលាបឋមសិក្សា មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាឯកជន ការអប់រំកុមារតូចតាមផ្ទះ និងក្រុមខ្ទងផ្ទះ និងមានកិច្ចសហការល្អរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងដៃគូអភិវឌ្ឍ ដើម្បីអភិវឌ្ឍការងារគាំពារ និងអប់រំកុមារតូច។

ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ សាលាមត្តេយ្យសិក្សាមាន ៥ ៨០៧ កន្លែង ក្នុងនោះមត្តេយ្យសិក្សារដ្ឋមាន ៣ ១៨៤ (មត្តេយ្យសិក្សាដាច់ដោយឡែក ២១១) មត្តេយ្យសិក្សាឯកជនមាន ៤០៣ និងមត្តេយ្យសិក្សាសហគមន៍មាន ២ ២២០ កន្លែង ។

កុមារអាយុពី ០ ទៅក្រោម ៦ ឆ្នាំ បានទទួលសេវាអប់រំមាន ៣២៨ ៧២៣ នាក់ ស្មើនឹង ១៧,៥៩ ភាគរយ នៃក្រុមអាយុ ស្រី ៤៩,៥០ ភាគរយ។ កុមារអាយុ ៣ឆ្នាំ មាន ១៦,៦៥ ភាគរយ ធៀបនឹងឆ្នាំសិក្សា ២០០៩-២០១០ មានត្រឹម ៨,៨៤ ភាគរយ។ កុមារអាយុ ៤ឆ្នាំ មាន ២៤,៨៧ ភាគរយ ធៀបនឹងឆ្នាំសិក្សា ២០០៩-២០១០ មានត្រឹម ១២,៩៤ ភាគរយ និងកុមារអាយុ ៥ឆ្នាំ មាន ៥៩,៩៣ ភាគរយ ធៀបនឹងឆ្នាំសិក្សា ២០០៩-២០១០ មានត្រឹម ៣៧,៥៩ ភាគរយ។ តាមតួលេខនេះ បង្ហាញថា កម្ពុជានឹងអាចសម្រេចបាននូវចំណុចដៅរបស់ខ្លួន ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨។




ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

## ៣.២ ការអប់រំបឋមសិក្សា

ក្រសួងបានរៀបចំគោលនយោបាយស្តីពីសាលាកុមារមេត្រី ដែលមានចក្ខុវិស័យផ្តល់ឱកាសឱ្យកុមារដល់វ័យ និងក្នុងវ័យសិក្សាទាំងអស់បានចូលរៀន និងរៀនយ៉ាងហោចណាស់ត្រឹមកម្រិតអប់រំមូលដ្ឋាន ប្រកបដោយគុណភាព និងប្រសិទ្ធភាព ដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈ រួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។





ក្រសួងបានអនុវត្តយុទ្ធសាស្ត្រជាច្រើនដែលរួមមាន៖ ការបង្កិតសាលារៀនទៅជិតផ្ទះប្រជាពលរដ្ឋ ការផ្តល់អាហារពេលព្រឹក និងអាហារូបករណ៍សម្រាប់សិស្សក្រីក្រ ការអនុវត្តកម្មវិធីអំណានថ្នាក់ទី១ ទី២ និងទី៣ ការផ្តល់មធ្យោបាយធ្វើដំណើរ ទោចក្រយានយន្ត និងកាណូតដល់ក្រុមបំប៉ន និងពិនិត្យតាមដាន ថ្នាក់ក្រុង ស្រុក ខណ្ឌ កម្មវិធីអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ ការអនុវត្តកម្មវិធីសាលាកុមារមេត្រី ការចុះជួយសាលារៀនទាន់ពេលវេលា ការបំពាក់សង្ហារឹម និងផ្តល់សៀវភៅអានដល់បណ្ណាល័យ។ កត្តាទាំងនេះបានធ្វើឱ្យមានកំណើនអត្រាចូលរៀន និងស្ថិរភាពនៃការសិក្សា បាន

ជួយសិស្សឱ្យមានមូលដ្ឋានរឹងមាំលើការអាន និងសរសេរ។ ក្រៅពីនេះ ក្រសួងបានផ្តល់ចំណេះដឹងដល់គ្រូក្នុងការកំណត់អត្តសញ្ញាណរកវិធីជួយកុមារពិការតាមប្រភេទ និងផ្តល់ឧបករណ៍ជំនួយដល់សិស្សពិការ ដើម្បីឱ្យការរៀនសូត្របានប្រសើរ។

ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ សាលាបឋមសិក្សាមាន ៦ ៩៩៣ ។ កម្រងសាលារៀនមាន ១ ២១២។ សាលាកុមារមេត្រីមាន ៥ ០៦៨ (កម្រិតមធ្យម និងអភិវឌ្ឍ) ស្មើនឹង ៧២,៤៧ ភាគរយ។ សាលា បឋមសិក្សាមិនគ្រប់កម្រិតមាន ៨១៦ ស្មើនឹង ១១,៦៧ ភាគរយ នៃចំនួនសាលាបឋមសិក្សាសរុប ។

សិស្សបឋមសិក្សាមាន ២ ០៧៣ ៨១១ នាក់ ស្រី ៤៧,៩៨ ភាគរយ។ អត្រាពិតនៃការសិក្សា ៩៨,២ ភាគរយ ស្រី ៩៨,៥ ភាគរយ។ អត្រាពិតចូលរៀនថ្មី ៩៨,១ ភាគរយ ស្រី ៩៨,២ ភាគរយ ក្នុងនោះអត្រាពិតចូលរៀនថ្មីរបស់សាលាឯកជន ២,៨ ភាគរយ ស្រី ២,៩ ភាគរយ។ អត្រាពិតនៃការសិក្សា ៩៨,២ ភាគរយ ស្រី ៩៨,៥ ភាគរយ ក្នុងនោះអត្រាពិតនៃការសិក្សារបស់សាលាឯកជន ២,៦ ភាគរយ ស្រី ២,៧ ភាគរយ។ អត្រាឡើងថ្នាក់ ៨៤,៧ ភាគរយ ស្រី ៨៧,៦ ភាគរយ។ អត្រាត្រួតថ្នាក់ ៤,៨ ភាគរយ ស្រី ៤,១ ភាគរយ។ អត្រាបោះបង់ការសិក្សា ១០,៥ ភាគរយ ស្រី ៨,៣ ភាគរយ។ អត្រាឆ្លងភូមិសិក្សា ៧៦,៨ ភាគរយ ស្រី ៨១,៤ ភាគរយ។ អត្រាបញ្ចប់ការសិក្សា ៨៨,៩៤ ភាគរយ ស្រី ៩០,១៩ ភាគរយ។

តាមតួលេខនេះ បានបង្ហាញថា កម្ពុជានឹងសម្រេចបាននូវគោលដៅអប់រំសម្រាប់ទាំងអស់គ្នានាឆ្នាំ២០១៥ ស្របតាមគោលដៅអភិវឌ្ឍសហស្សវត្ស(សកលកម្មអប់រំបឋមសិក្សា)។







ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

## ៣.៣ ការអប់រំនៅមធ្យមសិក្សា និងអប់រំបច្ចេកទេស

ក្រសួងបានរៀបចំគោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន ដែលមានចក្ខុវិស័យជាមជ្ឈមណ្ឌលឧត្តមភាពនៃការសិក្សា ដែលផ្តល់ឱកាសរៀនសូត្រដ៏ល្អប្រកបដោយសក្តានុពលដល់សហគមន៍សិក្សា និងកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំនៃចំណេះដឹង សំដៅសម្រេចបានលទ្ធផលខ្ពស់នៃចតុស្តម្ភអប់រំ សម្រាប់ការបណ្តុះបណ្តាល ផ្សព្វផ្សាយបន្ត និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព ផលិតភាព និងគុណធម៌។ នៅមធ្យមសិក្សា ក្រសួងបានផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ ដោយខិតខំបញ្ចូលកម្មវិធីអប់រំបណ្តុះសញ្ញាណវិជ្ជាជីវៈងាយៗ អនុវត្តកម្មវិធីសិក្សាប្រកបដោយភាពទន់ភ្លន់ ដែលអនុញ្ញាតឱ្យសិស្សចាប់ ពីថ្នាក់ទី ១១ ឡើងទៅ អាចជ្រើសរើសមុខវិជ្ជាតាម ឧបនិស្ស័យ និងចំណូលចិត្តរបស់ខ្លួនជាពីរផ្នែកគឺ ថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គម។ ការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សាបឋមភូមិបានចូលរួមបង្កើនប្រសិទ្ធភាពផ្ទៃក្នុង។ ការពិនិត្យតាមដានវាយតម្លៃ និងកែលម្អលើការងារដឹកនាំគ្រប់គ្រងការងារបង្រៀន និងរៀននាំឱ្យមានគុណភាពអប់រំ។ ក្រសួងបានពិនិត្យកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សា កសាងស្តង់ដារអប្បបរមាស្តីពីលទ្ធផលនៃការរៀនសូត្ររបស់សិស្ស ព្រមទាំងផ្គត់ផ្គង់សម្ភារៈ និងសៀវភៅសិក្សា ដើម្បីលើកកម្ពស់គុណភាពអប់រំ សម្រាប់ពេលបច្ចុប្បន្ន និងទៅអនាគត។

ក្រសួងបានរៀបចំ និងផ្សព្វផ្សាយគោលនយោបាយស្តីពីការអប់រំបច្ចេកទេស។ ក្រសួងបានរៀបចំក្របខណ្ឌ ផ្តល់វិញ្ញាបនបត្របណ្តោះអាសន្ន និងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ និងឯកសារអប់រំតម្រង់ទិសវិជ្ជាជីវៈសម្រាប់មធ្យមសិក្សាបឋមភូមិ។ កម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។




ក្រសួងបានបញ្ចូលការអប់រំបំណិនជីវិតមូលដ្ឋានទៅក្នុងកម្មវិធីសិក្សា ដែលរួមមានការអប់រំពាក់ព័ន្ធនឹងមុខរបរសិប្បកម្ម កសិកម្មតាមមូលដ្ឋាន ការអប់រំសីលធម៌ សុភាវធម៌រស់នៅ អនាម័យទូទៅ និងអនាម័យចំណីអាហារ ការដាំដុះ ការដេរប៉ាក់ ការដាំស្ល ការចិញ្ចឹមសត្វ រោងជាង ការថែរក្សា និង

ការពារបរិស្ថានតំបន់ឆ្នេរ ការបញ្ជ្រាបការយល់ដឹងអំពីជំងឺអេដស៍ គ្រុនផ្តាសាយបក្សី ការប្រឆាំង គ្រឿងញៀន ការជួញដូរផ្លូវភេទ ការកេងប្រវ័ញ្ចពលកម្មលើស្ត្រី-កុមារ ការយល់ដឹងពីគ្រាប់មីន និងអាវុធ យុទ្ធភណ្ឌមិនទាន់ផ្ទុះ និងការអប់រំជីវភាសា។ល។ ជាខ្លឹមសារបំណិនជីវិតដែលបានបញ្ជ្រាបចូលក្នុងកម្មវិធីសិក្សា ភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គម និងវិទ្យាសាស្ត្រ។

ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ គ្រឹះស្ថានមធ្យមសិក្សាមាន ១ ៦៨៨ ក្នុងនោះអនុវិទ្យាល័យ ១ ២៤៤ និងវិទ្យាល័យ ៤៤៤។ ក្នុងចំណោមវិទ្យាល័យទាំង ៤៤៤ មានវិទ្យាល័យធនធាន ២៩។ សាលាកុមារមេត្រីមធ្យមសិក្សាបឋមភូមិមាន ៩២៣ ស្មើនឹង ៥៥,៦៣ ភាគរយ នៃសាលារៀនដែលមានកម្រិតមធ្យមសិក្សាបឋមភូមិ។ សិស្សមធ្យមសិក្សាបឋមភូមិមាន ៥៣៨ ៦២៦ នាក់ ស្រី ៤៩,៧១ ភាគរយ។ អត្រារួមនៃការសិក្សា ៥៥,៣ ភាគរយ ស្រី ៥៦,២ ភាគរយ ក្នុងនោះអត្រារួមនៃការសិក្សាសាលាឯកជន ១,៨ ភាគរយ ស្រី ១,៧ ភាគរយ។ សិស្សមធ្យមសិក្សាទុតិយភូមិមាន ២៦៦ ២៩៣ នាក់ ស្រី ៤៧,៧០ ភាគរយ។ អត្រារួម នៃការសិក្សា ២៦,០ ភាគរយ ស្រី ២៥,៧ ភាគរយ ក្នុងនោះអត្រារួមនៃការសិក្សារបស់សាលាឯកជន ១,១ ភាគរយ ស្រី ១,១ ភាគរយ។

អនុវិទ្យាល័យឯកជនមាន ៣៥ សិស្សមាន ១ ៨២៨ នាក់ ស្រី ៥៦,៥ ភាគរយ។ វិទ្យាល័យឯកជនមាន ៨៧ សិស្សមាន ២៧ ៦៤៤ នាក់ ស្រី ៤៦,៩ ភាគរយ។ អនុវិទ្យាល័យ ៨៤,៨ ភាគរយ មានបង្គន់អនាម័យ និង ៤៨,៦ ភាគរយ មានទឹកស្អាត។ វិទ្យាល័យ ៩៨,០ ភាគរយ មានបង្គន់អនាម័យ និង ៦២,៦ ភាគរយ មានទឹកស្អាត។

សិស្សអាហារូបករណ៍មធ្យមសិក្សាបឋមភូមិមាន ៥៦ ៥៣៤ នាក់ ស្រី ៥៩,៧៥ ភាគរយ សិស្សអាហារូបករណ៍មធ្យមសិក្សាទុតិយភូមិមាន ៥ ៥១២ នាក់ គាំទ្រដោយថវិកាកម្មវិធីរបស់រាជរដ្ឋាភិបាល និងគម្រោងដៃគូអភិវឌ្ឍនានា។

លទ្ធផលប្រកួតប្រជែងអ្នកវិទ្យាសាស្ត្រអូឡាំពិចអន្តរជាតិវ័យក្មេងអាយុក្រោម ១៥ ឆ្នាំ បេក្ខជនកម្ពុជា ជាប់ជ័យលាភីមេដាយសំរឹទ្ធ ៣ នាក់។






សិស្សមធ្យមសិក្សាបឋមភូមិមាន ៥៣៨ ៦២៦ នាក់ ស្រី ៤៩,៧១ ភាគរយ។ អត្រារួមនៃការ

សិក្សា ៥៥,៣ ភាគរយ ស្រី ៥៦,២ ភាគរយ ក្នុងនោះអត្រារួមនៃការសិក្សាសាលាឯកជន ១,៨ ភាគរយ ស្រី ១,៧ ភាគរយ។ សិស្សមធ្យមសិក្សាទុតិយភូមិមាន ២៦៦ ២៩៣ នាក់ ស្រី ៤៧,៧០ ភាគរយ។ អត្រារួមនៃការសិក្សា ២៦,០ ភាគរយ ស្រី ២៥,៧ ភាគរយ ក្នុងនោះអត្រារួមនៃការសិក្សារបស់សាលាឯកជន ១,១ ភាគរយ ស្រី ១,១ ភាគរយ។







ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

## ៣.៤ ការអប់រំនៅឧត្តមសិក្សា

គ្រឹះស្ថានឧត្តមសិក្សាមាន ១០៥ (គ្រឹះស្ថានឯកជន) ធៀបនឹងឆ្នាំ២០១២។ ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំង ១០៥ មានគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៣៩ និងឯកជន ៦៦ ដែលមានទីតាំងនៅតាមរាជធានី ខេត្ត ១៩។ គ្រឹះស្ថានឧត្តមសិក្សា៦៥ (រដ្ឋ៩ និងឯកជន ៥៦) ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា និង ៤០ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ១៣ ផ្សេងទៀត។





និស្សិតកំពុងសិក្សាសរុប ២៥៣ ៧៦៤ នាក់ កើន ៩,៤៥ ភាគរយ ស្រី ៤០,១២ ភាគរយ ក្នុង

នោះ បរិញ្ញាបត្រ ២២៩ ៤១៤ នាក់ ស្រី ៤០,៥៨ ភាគរយ (និស្សិតអាហារូបករណ៍ ២៨ ៣៤៨ នាក់ ស្រី ៣៦,៤៦ ភាគរយ និងសិក្សាបង់ថ្លៃ ២០១ ០៦៦ នាក់ ស្រី ៤១,១៦ ភាគរយ) និងបរិញ្ញាបត្ររង ២៤ ៣៥០ នាក់ ស្រី ៣៥,៨០ ភាគរយ (អាហារូបករណ៍ ៤ ១០៣ នាក់ ស្រី ៣៧,២៩ ភាគរយ និងសិក្សាបង់ថ្លៃ ២០ ២៤៧ នាក់ ស្រី ៣៥,៥០ ភាគរយ)។

និស្សិតប្រឡងបញ្ចប់ការសិក្សា ៤៨ ៥៤៩ នាក់ ស្រី ៤០,៦៩ ភាគរយ ក្នុងនោះបរិញ្ញាបត្រ ៣៧ ៧៧៩ នាក់ ស្រី ៤១ ភាគរយ (អាហារូបករណ៍ ៤ ៩៨១ នាក់ ស្រី ៤៤,៤១ ភាគរយ និងបង់ថ្លៃសិក្សា ៣២ ៧៩៨ នាក់ ស្រី ៤០,៤៨ ភាគរយ) និងនិស្សិតបរិញ្ញាបត្ររង ១០ ៧៧០ នាក់ ស្រី ៣៩,៦១ ភាគរយ (អាហារូបករណ៍ ១ ៨៥០ នាក់ ស្រី ៤៦,៧៦ ភាគរយ និងសិក្សាបង់ថ្លៃ ៨ ៩២០ នាក់ស្រី ៣៨,១៣ ភាគរយ) ។






ទន្ទឹមនឹងបរិមាណនិស្សិតមានការកើនឡើង ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចគ្រឹះស្ថានឧត្តមសិក្សាបានយកចិត្តទុកដាក់ ក្នុងការពង្រឹងគុណភាពបណ្តុះបណ្តាល ដែលជាកត្តាកំណត់ជោគជ័យ សម្រាប់ការប្រកួតប្រជែងលើទីផ្សារពលកម្មទាំងក្នុងប្រទេស និងក្នុងតំបន់។

ក្រសួងបានរៀបចំគោលនយោបាយស្តីពីការស្រាវជ្រាវក្នុងវិស័យអប់រំ ដែលមានចក្ខុវិស័យកសាងធនធានមនុស្ស ដែលមានសមត្ថភាពខ្ពស់ទាំងចំណេះដឹង ជំនាញ សីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព សម្រាប់រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា ប្រកបដោយចីរភាពនៅក្នុងបរិបទសាកលភាវូបនីយកម្ម។

ក្រសួងបានយកចិត្តទុកដាក់ដល់សមធម៌នៃការចូលរៀននៅឧត្តមសិក្សា តាមរយៈការផ្តល់អាហារូបករណ៍ដល់និស្សិតក្រីក្រ និស្សិតនារី និងនិស្សិតដែលមកពីតំបន់ជនបទ។ ក្រសួងបានសាងសង់អគារអន្តេវាសិកដ្ឋានចំនួន ០៤ នៅរាជធានីភ្នំពេញ ដែលបានសម្ពោធដាក់ឱ្យ ប្រើប្រាស់ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** កាលពីពេលកន្លងមកនេះ សម្រាប់ឱ្យនិស្សិត នារី មកពីគ្រួសារក្រីក្រ និងមកពីខេត្តឆ្ងាយៗ បានស្នាក់នៅរៀនសូត្របន្ត។

## ៣.៥ ការអប់រំក្រៅប្រព័ន្ធ

ការងារអប់រំក្រៅប្រព័ន្ធជាប្រព័ន្ធអប់រំផ្លូវការមួយ រួមចំណែកសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា និងបង្កលទ្ធភាពឱ្យប្រជាជនមានឱកាសទទួលបាននូវការអប់រំពេញមួយជីវិត កសាងសង្គមសិក្សាប្រកបដោយសមធម៌ យុត្តិធម៌ និងអភិវឌ្ឍសង្គម។ អត្រាអក្ខរកម្មយុវជនអាយុ ១៥-២៤ ឆ្នាំបានកើនឡើងដល់ ៩២,០ ភាគរយ នៅឆ្នាំ ២០១២ កើន ៤ ភាគរយធៀបឆ្នាំ ២០០៨។




**កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ** ថ្នាក់អក្ខរកម្មមាន ១ ២៧៧ថ្នាក់ បានអនុវត្តនៅទូទាំងប្រទេស។ អ្នករៀនបានបញ្ចប់ និងទទួលប័ណ្ណអក្ខរកម្មវិជ្ជាជីវៈ ២៣ ២៧៧ នាក់ ស្មើនឹង ៧៩,០២ ភាគរយ ស្រី ៦៨,៣៥ ភាគរយ។ ក្នុងឆ្នាំ ២០១៣ ក្រសួងបានប្រារព្ធទិវាអក្ខរកម្មជាតិ អន្តរជាតិ ៨ កញ្ញា ក្រោមប្រធានបទ « អក្ខរកម្មរួមចំណែកអភិវឌ្ឍសហគមន៍ » អ្នកចូលរួម ១ ១១៧ នាក់ ស្រី ៤៤,៧៦ ភាគរយ។

**កម្មវិធីក្រោយអក្ខរកម្ម** បានអនុវត្តនៅទូទាំងប្រទេស មានបណ្ណាល័យ ៣៩ និងមណ្ឌលអាន ២៩៤ ក្នុងនោះបណ្ណាល័យ ៣៥ និងមណ្ឌលអាន ២៧៩ ដំណើរការ និងអ្នកចូលអាន ១១៤ ៩៣៨ នាក់ ស្រី ៥៩,២២ ភាគរយ ។

**កម្មវិធីចូលរៀនឡើងវិញ** បានអនុវត្តនៅទូទាំងប្រទេស លើកលែងខេត្តឧត្តរមានជ័យ។ សិស្ស ១៧ ៣៩៧ នាក់ ស្រី ៤៥,៩១ ភាគរយ។ សិស្សបានបញ្ចប់កម្មវិធី ១៥ ០៥២ នាក់ ស្រី ៤៥,៩៤ ភាគរយ និងបានបញ្ជូនចូលរៀនក្នុងសាលាចំណេះទូទៅវិញ ១៤ ៨៩៩ នាក់ ស្មើនឹង ៨៥,៦៤ ភាគរយ ស្រី ៤៥,៧០ ភាគរយ ។

**កម្មវិធីបង្កើនប្រាក់ចំណូលតាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍** បានអនុវត្តនៅទូទាំងប្រទេសមានមជ្ឈមណ្ឌលសិក្សាសហគមន៍ ៣៤៨ ក្នុងនោះ ៣២៣ ដំណើរការថ្នាក់ជំនាញមាន ៦៤២។ អ្នកសិក្សាមាន ១០ ៨៩៣ នាក់ ស្រី ៥៨,២៥ ភាគរយ និងបានបញ្ចប់ ៧ ៧០៣ នាក់ ស្មើនឹង ៧០,៧១ ភាគរយ ស្រី ៦២,៤៩ ភាគរយ ។

**កម្មវិធីកែលម្អគុណភាពនៃជីវិតតាមរយៈសាលារៀនចល័ត** បានបង្រៀនអំពីបំណិនជីវិតតាមរយៈ រថយន្តចល័ត ១៣ លើក នៅ ១៣ ខេត្ត មានអ្នកចូលរួម ១ ៨៥៩ នាក់ ស្រី ៧១ ភាគរយ ។

**កម្មវិធីសមមូល-បំពេញវិជ្ជា** កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ បានអនុវត្តនៅរាជធានី ភ្នំពេញ ខេត្តព្រះសីហនុ និងសៀមរាបមាន ១៥ថ្នាក់ សិស្សចូលរៀន ៧៥៩ នាក់ ស្រី ៥៥,៤៦ ភាគរយ និងបានបញ្ចប់ ៧៥៩ នាក់ ស្មើនឹង ១០០ ភាគរយ ស្រី ៥៥,៤៦ ភាគរយ ។

ក្រសួងបានពង្រឹង និងពង្រីកការផ្សព្វផ្សាយសកម្មភាពអប់រំក្រៅប្រព័ន្ធតាមវិទ្យុ និងទូរទស្សន៍ជាតិ និងបានចុះបង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ តាមរថយន្តសាលារៀនចល័ត។

## ៣.៦ ការងារយុវជន

រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា មានចក្ខុវិស័យប្រមូលផ្តុំកម្លាំងគ្រប់មជ្ឈដ្ឋានក្នុងសង្គមជាតិ សំដៅរួមចំណែកអភិវឌ្ឍយុវជនឲ្យកាន់តែមានលក្ខណៈសម្បត្តិវិជ្ជមាន និងផ្តល់ឱកាសឲ្យពួកគេអភិវឌ្ឍសក្តានុពលនៅក្នុងការអប់រំ ការងារសុខភាព ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួមចំណែកអភិវឌ្ឍគ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួងបានដាក់ឱ្យអនុវត្តចលនាបីល្អ " កូនល្អ សិស្សល្អ មិត្តល្អ " របស់កុមារ យុវជននៅតាមសាលារៀនទូទាំងប្រទេស។ ក្រសួងបានរៀបចំការបោះជំរំយុវជនជាសាកលដោយ មានយុវជនមកពីគ្រឹះស្ថានឧត្តមសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា និងនិស្សិតបរទេសដើមកំណើតខ្មែរ និងទស្សនកិច្ចសិក្សាប្រតិភូកុមារ យុវជនជារៀងរាល់ឆ្នាំ។





ក្រសួងបាន និងកំពុងដំណើរការអនុវត្ត ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ដើម្បីជំរុញកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ពន្ធ័ក្នុងការងារអភិវឌ្ឍយុវជន។ ជាមួយនោះ ក្រសួងបានសហការជំរុញចលនា កាយរិទ្ធចូលរួម ក្នុងការងារ សង្គមដូចជា ការសម្រួលចរាចរ អប់រំសីលធម៌ដល់យុវវ័យ ការថែទាំ បរិស្ថាន និងជួយការងារ ផ្សេងៗទៀតរបស់សហគមន៍។

ក្រសួងបានសិក្សាវាយតម្លៃពីតម្រូវការនៃការបណ្តុះបណ្តាល ដល់មន្រ្តីគ្រប់គ្រងយុវជន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្រសួងបានបណ្តុះបណ្តាលវគ្គជំនាញខ្លីៗ ស្តីពីសហគ្រិនភាព និងស្មារតីស្ម័គ្រចិត្តដល់យុវជននៅតាមមជ្ឈមណ្ឌលយុវជន និងសហការជាមួយអង្គការសម្ព័ន្ធយុវជន អន្តរជាតិ រៀបចំការ បោះជំរំយុវជន អន្តរជាតិ អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ រៀបចំវេទិកាជាតិលើកទី២ ស្តីពីការស្ម័គ្រចិត្ត និងប្រារព្ធទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត ៥ ធ្នូ ។

## ៣.៧ ការងារអប់រំកាយ និងកីឡា

រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយជាតិស្តីពីការអប់រំកាយ និងកីឡា ដែលមានចក្ខុវិស័យកសាងមនុស្សគ្រប់រូបឲ្យមានសុខភាព និងសុខុមាលភាពល្អ កាយសម្បទាមាំមួន ឆន្ទៈមោះមុត អំណត់ព្យាយាម វិន័យ ស្មារតីក្រុម គំនិតច្នៃប្រឌិត និងតស៊ូស្វិតស្វាញ សំដៅដណ្តើមបានលទ្ធផលល្អប្រសើរលើការប្រកួត និងជីវភាពរស់នៅសុខដុមរមនា។





ក្រសួងបានបំផុសសកម្មភាពអប់រំកាយក្នុងម៉ោងសិក្សាគ្រប់ភូមិសិក្សា និងប្រកួតកីឡាជ្រើសរើសជើងឯកបឋមសិក្សាថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ ការប្រកួតកីឡាជ្រើសរើសជើងឯក មធ្យម

សិក្សាថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ ការប្រកួតជ្រើសរើសជើងឯកមធ្យមសិក្សាឯកទេស និងឧត្តមសិក្សា។ ក្រសួងបានរៀបចំសកម្មភាព " កីឡាដើម្បីទាំងអស់គ្នា " ដើម្បី សុខភាព សាមគ្គីភាព និងការជួបជុំសម្រាប់មហាជនទូទៅ ព្រមទាំងបានបន្តស្តារឡើងវិញនូវកីឡាប្រពៃណីផងដែរ ។

ក្រសួងបានរៀបចំការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ភូមិភាគ ថ្នាក់ជាតិ និងបានជួសជុលកែលម្អលានកីឡានៅតាមរាជធានី ខេត្ត។ ក្រសួងបានប្រមូលផ្តុំក្រុមកីឡាជម្រើសជាតិហាត់ហ្វឹកហ្វឺន និងបញ្ជូនទៅចូលរួមប្រកួតកីឡាជាលក្ខណៈអន្តរជាតិនានា និងបានទទួលមេដាយមាស១៦ មេដាយប្រាក់១៨ និងមេដាយសំរិទ្ធ ៤៩ ក្នុងការប្រកួតកីឡាស៊ីហ្គេម អាស៊ីហ្គេម និងការប្រកួតអន្តរជាតិនានាជាច្រើនទៀត។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលបានផ្តល់ប្រាក់រង្វាន់ជូនជ័យលាភីតាមគោលការណ៍របស់រដ្ឋដែលបានកំណត់។





## ៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការលើកកម្ពស់កិច្ចសហប្រតិបត្តិការវិស័យអប់រំ យុវជន និងកីឡា ត្រូវបានធ្វើឡើង តាមរយៈការអនុវត្តកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ជាពិសេសបណ្តាប្រទេសជាសមាជិកស៊ីមេអូ-អាស៊ាន ប្រាង់កូហ្វូនី ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សអន្តរជាតិ ព្រមទាំងវិស័យឯកជនផង ក្រោមរូបភាពកិច្ចសហប្រតិបត្តិការ អប់រំទ្វេភាគី និងពហុភាគី។

## ដោយផ្នែកកិច្ចសហប្រតិបត្តិការកម្ពុជា-កូរ៉េ

ក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំក្រុងប៊ូសាននៃសាធារណរដ្ឋកូរ៉េ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ក្នុងវិស័យអប់រំ តាមរយៈការកសាងសមត្ថភាពគ្រូបង្រៀននៅក្របខ័ណ្ឌមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ និងផ្ដល់កុំព្យូទ័រជូនដល់សាលារៀនគោលដៅសម្រាប់បម្រើដល់ការរៀន និងបង្រៀន។





ក្រសួងអប់រំ យុវជន និងកីឡា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បានចុះហត្ថលេខាលើកំណត់ហេតុពិភាក្សា (Record of discussion) ស្ដីពីគម្រោងកសាងមជ្ឈមណ្ឌលអភិវឌ្ឍធនធានមនុស្សកម្ពុជា ដែលមានទីតាំងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមការឧបត្ថម្ភថវិកាពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) មជ្ឈមណ្ឌលនេះបានដាក់ឈ្មោះថា មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការ កម្ពុជា-កូរ៉េ ( Cambodia-Korea Cooperation Center ) និងបានដាក់ឱ្យដំណើរការហើយ។



ក្រសួងអប់រំ យុវជន និងកីឡា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បានចុះហត្ថលេខាលើកំណត់ហេតុពិភាក្សា (Record of discussion) ស្តីពីការបង្កើត The Project for Strengthening the CLMV Capacity for the ASEAN - ROK CYBER University in Cambodia នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានដាក់ឱ្យដំណើរការហើយ។





សិក្ខាសាលាលើកទី២ ស្តីពីការអភិវឌ្ឍការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងលោកស្រី Baek Sook Hee តំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (កូយកា) នៅសណ្ឋាគារភ្នំពេញ ចាប់ពីថ្ងៃទី៣០ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤។





ចាប់តាំងពីឆ្នាំ ២០០៣ ក្រសួងអប់រំ យុវជន និងកីឡា បានទទួលអ្នកស្ម័គ្រចិត្តទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) នៅកម្ពុជាចំនួន ១៨៦ នាក់ ក្នុងនោះ ចំនួន ៥១ នាក់ បាននិងកំពុងបំពេញការងារក្នុងវិស័យអប់រំ នាពេលបច្ចុប្បន្ន ស្មើនិង ៨១ ភាគរយ នៃចំនួនអ្នកស្ម័គ្រចិត្តទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ដែលកំពុងបំរើការនៅកម្ពុជា។






## ៥. ទិសដៅការកំណែទម្រង់ក្នុងវិស័យអប់រំ យុវជន និងកីឡា

ផ្អែកលើគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ក៏ដូចជាអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** លើការកែទម្រង់ស៊ីជម្រៅគ្រប់វិស័យសម្រាប់រាជរដ្ឋាភិបាលអាណត្តិទី ៥ នៃរដ្ឋសភា ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានការអាទិភាពសម្រាប់កែទម្រង់វិស័យអប់រំ យុវជន និងកីឡា ចំនួនប្រាំបីចំណុច៖

- *ការពង្រឹងការគ្រប់គ្រងបុគ្គលិក* ៖ អនុវត្តកំណែទម្រង់មុខងារសាធារណៈ បង្កើនបៀវត្សនិង ធានាការ តែងតាំងមន្ត្រីរាជការ ដោយឈរលើមូលដ្ឋានសមិទ្ធកម្ម ។
- *ការលើកកម្ពស់គុណភាពនៃការអប់រំ* ៖ បង្កើតក្របខ័ណ្ឌថ្នាក់ជាតិសម្រាប់ធានាការពិនិត្យតាមដានគុណភាព និងយន្តការនានាសម្រាប់អនុវត្ត។ រួមបញ្ចូលទាំងយន្តការសម្រាប់វាស់វែងលទ្ធផលនៃការសិក្សារបស់សិស្ស តាមរយៈការធ្វើតេស្តនៅតាមថ្នាក់រៀនជាប្រចាំ ការវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ទី ៣ ព្រមទាំងពង្រីកទៅដល់ថ្នាក់ទី ៦ និងទី ៨។ លើកកម្ពស់

គុណភាព និងភាពឆ្លើយតបនៃការសិក្សា តាមរយៈការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងសម្ភារៈសិក្សាជាទៀងទាត់ និងមានលក្ខណៈជាប្រព័ន្ធ។

- *ការពង្រឹងរាល់ដំណើរការប្រឡងគ្រប់ប្រភេទ* ៖ ពង្រឹងគុណភាពប្រឡងដោយអនុវត្ត គោលការណ៍ ៤ យ៉ាង គឺគោលការណ៍ ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន។
- *កំណែទម្រង់ឧត្តមសិក្សា* ៖ កែទម្រង់ប្រព័ន្ធអប់រំនៅឧត្តមសិក្សាឱ្យមានលក្ខណៈជាប្រព័ន្ធ ស្របជាមួយនឹងស្តង់ដារក្នុងតំបន់ និងអន្តរជាតិ លើកកម្ពស់គុណភាពនៃដំណើរការរបស់ប្រព័ន្ធ ការបង្រៀននិងស្រាវជ្រាវលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា។
- *កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុអប់រំ និងហិរញ្ញប្បទាន* ៖ អភិវឌ្ឍសមត្ថភាពក្នុងការរៀបចំ និងការអនុវត្តថវិកា ការដេញថ្លៃ ការធ្វើវិមជ្ឈការថវិកាដល់សាលារៀន ការកែលម្អការ គ្រប់គ្រងហិរញ្ញវត្ថុ និងការពង្រឹងការងារសវនកម្ម។
- *ការអភិវឌ្ឍជំនាញបច្ចេកទេស និងជំនាញទន់សម្រាប់យុវជន* ៖ បង្កើនការចូលរៀនផ្នែកអប់រំ បច្ចេកទេស និងផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា។ ការប្រកួតប្រជែងជំនាញបច្ចេកទេស សំដៅត្រៀមលក្ខណៈសម្រាប់សមាហរណកម្មអាស៊ានក្នុងឆ្នាំ ២០១៥ ដើម្បីឆ្លើយតបបានទៅនឹងសេចក្តីត្រូវការទីផ្សារពលកម្ម និងបង្កើនឱកាសទទួលបានការងារ។
- *ការអភិវឌ្ឍការអប់រំកាយ និងកីឡាដើម្បីត្រៀមរៀបចំកីឡាស៊ីហ្គេមនៅឆ្នាំ២០២៣* ៖ រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍវិស័យកីឡា និងយន្តការសម្រាប់ អនុវត្ត ។
- *ការបង្កើតក្រុមប្រឹក្សាស្រាវជ្រាវអប់រំ* ៖ រៀបចំក្រុមប្រឹក្សាស្រាវជ្រាវអប់រំ និងកសាងឯកសារ ទស្សនទានស្តីពីការបង្កើតក្រុមប្រឹក្សាស្រាវជ្រាវអប់រំ។